មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## ឃាតកម្មលើអ្នកសារព័ត៌មានដែលរាយការណ៍ពីករណីនេសាទខុសច្បាប់នៅក្នុងខេត្តកំពង់ឆ្នាំង គឺជាការប្រមាថលើសេរីភាពបញ្ចេញមតិនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ថ្កោលទោសចំពោះមរណភាពនៅចុងសប្តាហ៍នេះរបស់អ្នកសារព័ត៌មាននៃកាសែតជាខេមរៈភាសា ឈ្មោះ *មាគ៌ាកម្ពុជា* គឺលោក សួន ចាន់ នៅស្រុកជលគីរី ខេត្តកំពង់ឆ្នាំង។ មរណភាពរបស់លោកសួន ចាន់ គឺជាការប្រមាថមួយផ្សេងទៀតលើសេរីភាពក្នុងការបញ្ចេញមតិ ហើយជាពិសេសលើសេរីភាពសារព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ខណៈពេលដែលអ្នកសារព័ត៌មានជានិច្ចជាកាលត្រូវបានគេដៅមុខចំពោះការងាររបស់ពួកគេ និងខណៈពេលដែលវប្បធម៌និទណ្ឌភាពចំពោះបទល្មើសនានាកំពុងរីករាលដាល។ យោងតាមអត្ថបទកាសែត *ភ្នំពេញប៉ុស្តិ៍* ដែលមានចំណងជើងថា ("អ្នកសារព័ត៌មានត្រូវបានវាយសម្លាប់នៅខេត្តកំពង់ឆ្នាំង" ចុះផ្សាយនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤) អាជ្ញាធរមូលដ្ឋានជឿថា លោក សួន ចាន់ ត្រូវបានក្រុមអ្នកនេសាទមូលដ្ឋានសម្លាប់ ដោយសារតែការងាររាយការណ៍ពីបទល្មើសនេសាទខុសច្បាប់នៅក្នុងតំបន់នោះទេ។

លោក សួន ចាន់ គឺជាអ្នកសារព័ត៌មានទី១២ហើយ ដែលត្រូវបានឃាតករសម្លាប់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាអ្នកសារព័ត៌មានដំបូងចាប់តាំងពីករណីលោក ហង្ស សេរីឧត្តម ត្រូវឃាតករធ្វើឃាតកាលពីខែកញ្ញា ឆ្នាំ២០១២ នៅខេត្តរតនៈគីរី។ ភាគច្រើននៃការស្លាប់អ្នកសារព័ត៌មានទាំងនេះ មិនត្រូវបានអាជ្ញាធរស៊ើបអង្កេតឲ្យបានត្រឹមត្រូវនោះទេ ដោយសារជនដៃដល់នៅពុំទាន់បានចាប់ខ្លួន ហើយថែមទាំងបានទទួលនូវនិទណ្ឌភាពចំពោះអំពើឧក្រិដ្ឋរបស់ពួកគេ។ ម.ស.ម.ក ជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ធានាថាការស៊ើបអង្កេតដោយពេញលេញ និងឯករាជ្យចំពោះការស្លាប់របស់លោក សួន ចាន់ ត្រូវបានធ្វើឡើង និងធានាថា ជនដៃដល់ត្រូវបាននាំយកមកកាត់ទោស ដែលនេះពុំមែនត្រឹមតែជានានូវយុត្តិធម៌សម្រាប់ក្រុមគ្រួសាររបស់លោក សួន ចាន់ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់នូវវប្បធម៌នៃការគោរព និងការការពារដល់អ្នកសារព័ត៌មាន និងការងាររបស់ពួកគេ។

**កញ្ញា ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក មានប្រសាសន៍ថា៖**

*"ជួសមុខឲ្យបុគ្គលិកទាំងអស់នៅ ម.ស.ម.ក ខ្ញុំសូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំដល់ក្រុមគ្រួសាររបស់លោក សួន ចាន់។ ករណីនេះ ក្រើនរម្លឹកយើងថា ស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិ ជាពិសេសសេរីភាព*

*ខាងសារព័ត៌មាននៅកម្ពុជាមានសភាពធ្ងន់ធ្ងរ៖ អ្នកសារព័ត៌មានជានិច្ចជាកាលត្រូវបានយាយី ត្រូវបាននាំយកទៅកាត់ទោសក្រោមបទចោទប្រកាន់ដោយហេតុផលនយោបាយ និងត្រូវបានឃាតកសម្លាប់ដ៏គួរឲ្យសោកសង្រេងបំផុត។ ប៉ុន្តែការស្លាប់របស់លោក សួន ចាន់ មិនត្រឹមតែបង្ហាញពីការមិនគោរពចំពោះសេរីភាពបញ្ចេញមតិប៉ុណ្ណោះទេ ថែមទាំងបង្ហាញឲ្យឃើញនូវវប្បធម៌ទិណ្ឌភាពដ៏រីករាលដាលខណៈពេលដែលជនណាម្នាក់អាចសម្រេចចិត្តប្រព្រឹត្តអំពើមនុស្សឃាតដោយដឹងជាមុនថា ខ្លួនប្រហែលនឹងមិនត្រូវបាននាំយកទៅផ្តន្ទាទោសនោះទេ។ ការស៊ើបអង្កេតដោយតម្លាភាពចំពោះឃាតកម្មលើរូបលោក សួន ចាន់ គឺពិតជាមានសារៈសំខាន់ណាស់ បើពុំមានការស៊ើបអង្កេតនោះទេ ស្ថានភាពរបស់អ្នកសារព័ត៌មាននឹងកាន់តែបន្តធ្លាក់ដុនដាបទៅ។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងគាំទ្រអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ ០១៧ ៥២៨ ០២១ ឬតាមរយៈអ៊ីម៉ែល៖ chhunly.chhay@cchrcambodia.orgឬ កញ្ញា ហ្សូលីយ៉ែត រ៉ូស្សេឡូត តាមទូរសព្ទ៖+៨៥៥ (០) ១៥ ៣៥០ ៦២០ ឬអ៊ីម៉ែល៖ julietterousselot@cchrcambodia.org។**

ចប់

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។
ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្ម ពិភពលោក (OMCT) ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងជ័យលាភីបានទទួលពានរង្វាន់ផ្នែកទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនឡែន ក្នុងរដ្ឋប្រ៊ីសបែន ប្រទេសអូស្ត្រាលី។